
www.kidsofdestiny.org
Kids of Destiny®
Reaching the Next Generation

1.08 កំណើតអ៊ីសាក

តាំងពីយូរយារណាស់មកហើយ មានបុរសម្នាក់ឈ្មោះអ័ប្រាហាំ ។ គាត់មានប្រពន្ធឈ្មោះសារ៉ា ។ ពួកគេរស់នៅក្នុងស្រុកខារ៉ានជាកន្លែងដែលពួកគេបានធំឡើង ។ ថ្ងៃមួយព្រះទ្រង់បានមានបន្ទូលទៅកាន់អ័ប្រាហាំថាទ្រង់មានសារពិសេសណាស់ដើម្បីផ្តល់ឱ្យគាត់ ។ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា "ចូរចាកចេញពីស្រុករបស់ឯង ក្រុមគ្រួសារ និងផ្ទះឪពុករបស់ឯង ដើម្បីទៅទឹកដីដែលយើងនឹងបង្ហាញឯង ។ យើងនឹងឱ្យពរ និងប្រជាជាតិដ៏អស្ចារ្យមួយដល់ឯង ។ ហើយគ្រួសារទាំងអស់នៅលើផែនដី នឹងត្រូវបានប្រទានពរដោយសារឯង ចូរឯងស្តាប់បង្គាប់ដល់យើង ។

អ័ប្រាហាំ និងសារ៉ាបានប្រមូលទ្រព្យសម្បត្តិរបស់ពួកគេ ហើយធ្វើតាមអ្វីដែលព្រះទ្រង់បានបង្គាប់ ។ ពួកគេបានទៅដល់ទឹកដីស្រុកកាណាន ។ លោកអ័ប្រាហាំមានអាយុ៧៥ឆ្នាំនៅពេលនោះ ។ ព្រះទ្រង់បានប្រាប់ដល់អ័ប្រាហាំថា ទ្រង់នឹងប្រគល់ទឹកដីនេះដល់កូនចៅរបស់គាត់ ។

ឥឡូវនេះ អ័ប្រាហាំជាអ្នកមានណាស់ ។ គាត់មានទ្រព្យសម្បត្តិជាច្រើន ។ គាត់ក៏មានអ្នកបម្រើជាច្រើនដែរ ។ នៅថ្ងៃមួយ អ័ប្រាហាំបានទូលទៅកាន់ព្រះថា៖ «តើទ្រព្យសម្បត្តិទាំងអស់នេះមានប្រយោជន៍ដល់ខ្ញុំយ៉ាងដូចម្តេចទៅ នៅពេលដែលខ្ញុំគ្មានកូនទុកវានៅពេលខ្ញុំស្លាប់ទៅ? តើត្រូវទុកទ្រព្យសម្បត្តិខ្ញុំឲ្យអ្នកបំរើឬ? ព្រះទ្រង់បានប្រាប់គាត់កុំឲ្យបារម្ភឡើយ ។ «មើលផ្កាយចុះ! អ័ប្រាហាំអើយ! រាប់ពួកវាប្រសិនបើឯងអាច ។ នោះគឺជាចំនួនកូនចៅដែលឯងនឹងមានហើយ ។ ឯងនឹងមានគ្រួសារដ៏ធំមួយ" ។ អ័ប្រាហាំជឿលើព្រះអម្ចាស់ ។ នោះពិតជាសំខាន់ណាស់ ។

ព្រះទ្រង់បានបន្តប្រាប់អ័ប្រាហាំ អំពីគ្រួសារដែលគាត់នឹងមាន ។ ព្រះទ្រង់បានប្រាប់អ័ប្រាហាំថា នឹងមានបញ្ហាជាច្រើន ។ ប្រជាជននឹងមិនស្តាប់បង្គាប់ព្រះអម្ចាស់ទេ ។ ប៉ុន្តែ ព្រះនៅតែប្រទានទឹកដីកាណានឲ្យដល់ពួកគេ ។

សារ៉ាមិនជឿដូចអ័ប្រាហាំអំពីការមានកូនទេ ។ អ័ប្រាហាំក៏មានការសង្ស័យខ្លះដែរ ។ គាត់មានអាយុ១០០ឆ្នាំហើយ ។ សារ៉ាមានអាយុ៩០ឆ្នាំ ។

នៅថ្ងៃមួយបុរសបីនាក់បានទៅលេងអ័ប្រាហាំ ។ គាត់បានអញ្ជើញពួកគេចូលក្នុងតង់របស់គាត់ ។ សារ៉ាក៏បានធ្វើនំប៉័ងខ្លះ ។ ពួកគេក៏មានសាច់អាំងទឹកដោះគោជូរនិងទឹកដោះគោផងដែរ ។ តើនេះជាពិធីអ្វីទៅ! បុរសម្នាក់បាននិយាយថា "ឆ្នាំក្រោយអ្នកនិងប្រពន្ធរបស់អ្នកនឹងមានកូនប្រុសម្នាក់!"

សារ៉ាបានសើច ។ តើស្ត្រីចំណាស់ដូចខ្ញុំអាចមានកូនយ៉ាងម៉េចទៅ? ជាពិសេស ប្តីរបស់ខ្ញុំក៏ចាស់ណាស់ដែរ ។ ព្រះអម្ចាស់បានឮសារ៉ាសើច ។ ហេតុអ្វីបានជាអ្នកសើចដូច្នេះ? ទ្រង់បានសួរ ។ "តើមានអ្វីដែលពិបាកសំរាប់ព្រះអម្ចាស់ទេ?"

ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «យើងបានរើសអ័ប្រាហាំឲ្យទទួលពរ ។ កូនៗរបស់ឯងនឹងក្លាយជាប្រជាជាតិមួយដ៏អស្ចារ្យនិងខ្លាំងក្លា ។ ជាតិសាសន៍ទាំងអស់នៅលើផែនដីនឹងទទួលពរតាមរយៈឯង ។ យើងបានជ្រើសរើសឯងដើម្បីឲ្យកូនប្រុស និងក្រុមគ្រួសាររបស់ឯងគោរពតាមមាគ៌ារបស់ព្រះអម្ចាស់ ដោយប្រព្រឹត្តត្រឹមត្រូវ ។ យើងនឹងធ្វើអ្វីៗទាំងអស់ ដែលយើងបានសន្យាចំពោះអ័ប្រាហាំ" ។

ព្រះអម្ចាស់ទ្រង់បានរក្សាការសន្យារបស់ទ្រង់ចំពោះអ័ប្រាហាំ ។ ប្រហែលជាមួយឆ្នាំក្រោយមក សារ៉ាបានបង្កើតកូនប្រុសមួយឲ្យអ័ប្រាហាំ ពេលគាត់មានអាយុចាស់ដូចព្រះបានប្រាប់មែន ។ អាប្រាហាំដាក់ឈ្មោះកូនប្រុសរបស់ពួកគេថា អ៊ីសាក ដែលមានន័យថា អ្នកចំអក ។

សារ៉ារីករាយណាស់! នាងនិយាយថា" ព្រះអម្ចាស់ទ្រង់បានធ្វើឲ្យខ្ញុំសើច! តើអ្នកណានឹងដឹងថា ខ្ញុំនឹងមានកូន? ខ្ញុំបានផ្តល់កូនប្រុស១ដល់អ័ប្រាហាំនៅអាយុចាស់ជរា! » ។

ព្រះទ្រង់អាចធ្វើគ្រប់ការទាំងអស់បាន ។

(លោកុប្បត្តិ ១២, ១៥, ១៨ និង ២១)

1.08 កំណើតអ៊ីសាក់ - **សេចក្តីណែនាំរបស់គ្រូបង្រៀន**

កំណត់សម្គាល់:

១) ព្រះទ្រង់បានស្នើសុំឱ្យអ័ប្រាហាំនិងភរិយារបស់គាត់ឈ្មោះសារ៉ា ចាកចេញពីផ្ទះរបស់ពួកគេ ហើយផ្លាស់ទៅទឹកដីដែលហៅថា ស្រុកកាណាន ។

២) ព្រះទ្រង់បានប្រាប់អ័ប្រាហាំថា គាត់នឹងមានកូនចៅជាច្រើន ដូចជាផ្កាយនៅលើមេឃ ។

៣) បុរស៣នាក់បានទៅលេងអ័ប្រាហាំ ។ បុរសម្នាក់ក្នុងចំណោមបុរសទាំងនោះបានប្រាប់អ័ប្រាហាំថា នៅពេលនេះ ឆ្នាំក្រោយ អ័ប្រាហាំនិងប្រពន្ធរបស់គាត់នឹងមានកូនប្រុសម្នាក់ ។

៤) សារ៉ាមិនជឿបុរសទាំនោះទេ ។ នាងបានសើច ។ នាងគិតថានាង និងអ័ប្រាហាំមានអាយុចាស់ណាស់ទៅហើយក្នុងការមានកូន ។

៥) ព្រះបានរក្សាការសន្យារបស់ទ្រង់ ។ នៅឆ្នាំបន្ទាប់អ័ប្រាហាំនិងសារ៉ាក៏មានកូនប្រុសម្នាក់ ។ អ័ប្រាហាំដាក់ឈ្មោះថាអ៊ីសាក់ ។

សំណួរ:

១) ហេតុអ្វីអ័ប្រាហាំ និងសារ៉ាចាកចេញពីផ្ទះ?
២) តើព្រះបានប្រាប់អ័ប្រាហាំថាគាត់នឹងមានកូនចៅប៉ុន្មាននាក់?
៣) តើភ្ញៀវម្នាក់ក្នុងចំណោមភ្ញៀវ ៣នាក់ បានប្រាប់អ័ប្រាហាំអំពីអ្វី?
៤) ហេតុអ្វីបានជាសារ៉ាសើច?
៥) តើព្រះបានធ្វើតាមការសន្យារបស់ទ្រង់ទេ?
៦) តើទារកនោះមានឈ្មោះអ្វី?

ចម្លើយ:

១) អ័ប្រាហាំ និងសារ៉ាបានចាកចេញពីផ្ទះរបស់ពួកគេ ពីព្រោះព្រះបានស្នើសុំដល់ពួកគេ ។
២) ព្រះទ្រង់បានប្រាប់អ័ប្រាហាំថាកូនចៅរបស់គាត់នឹងមានចំនួនដូចជាផ្កាយនៅលើមេឃ ។
៣) ភ្ញៀវម្នាក់បានប្រាប់អ័ប្រាហាំថាគាត់ និងសារ៉ានឹងមានកូនប្រុសម្នាក់នៅឆ្នាំបន្ទាប់ ។
៤) សារ៉ាសើចព្រោះនាងគិតថា នាងនិងអ័ប្រាហាំចាស់ពេកមិនអាចមានកូនបាន ។
៥) ព្រះទ្រង់បានរក្សាការសន្យារបស់ទ្រង់!
៦) ទារកនោះមានឈ្មោះអ៊ីសាក ។



www.kidsofdestiny.org